Australian Government
Australian Taxation Office

# ព័ត៌មានសំខាន់ៗសម្រាប់ការទូទាត់ពន្ធឆ្នាំ 2023-24របស់អ្នក។

ព័ត៌មានសំខាន់ៗខាងក្រោមជួយក្នុងការដាក់ពាក្យទូទាត់ពន្ធរបស់អ្នកសម្រាប់ឆ្នាំចំណូល2023-24 កាន់តែងាយស្រួល។

## ពេលវេលាល្អបំផុតដើម្បីដាក់ពាក្យទូទាត់ពន្ធ

និយោជក ធនាគារ និងទីភ្នាក់ងារផ្សេងទៀតរាយការណ៍ព័ត៌មានទៅការិយាល័យពន្ធដារអូស្ត្រាលី (ATO)។ ប្រសិនបើអ្នករង់ចាំរហូតដល់ចុងខែកក្កដា ដើម្បីដាក់ពាក្យទូទាត់ពន្ធរបស់អ្នកនោះ ATOនឹងបំពេញព័ត៌មាននេះជាមុនសម្រាប់អ្នក។ ការធ្វើបែបនេះធ្វើឱ្យការដាក់ពាក្យទូទាត់ពន្ធរបស់អ្នកកាន់តែលឿន ងាយស្រួល និងត្រឹមត្រូវជាង។ អ្នកដែលមិនរង់ចាំការបំពេញព័ត៌មានជាមុន ការទូទាត់ពន្ធរបស់ពួកគេអាចនឹងមានការពន្យាពេលនៅក្នុងប្រព័ន្ធ ហើយត្រូវកែប្រែការទូទាត់ពន្ធរបស់ពួកគេ ពីព្រោះប្រាក់ចំណូលរបស់ពួកគេទាំងអស់មិនបានដាក់បញ្ចូលក្នុងប្រព័ន្ធទេ។

## ប្រាក់ចំណូលដែលអ្នកត្រូវដាក់បញ្ចូលក្នុងរបាយការណ៍ទូទាត់ពន្ធរបស់អ្នក។

អ្នកត្រូវតែដាក់បញ្ចូលប្រាក់ចំណូលទាំងអស់ដែលអ្នកទទួលបានក្នុងអំឡុងឆ្នាំហិរញ្ញវត្ថុ។ នោះមានន័យថាប្រាក់ដែលអ្នកទទួលបានពីការងារទាំងអស់របស់អ្នក រួមទាំងការងារពេញម៉ោង កាងារមិនពេញម៉ោង ការងារបណ្ដែត ឬការងារដោយខ្លួនឯង និងការងារយកសាច់ប្រាក់។ អ្នកក៏ត្រូវតែដាក់បញ្ចូលប្រាក់ដែលអ្នករកបានតាមវិធីផ្សេងទៀតផងដែរ ដោយរួមមាន:

- សកម្មភាពអនឡាញ
- សេដ្ឋកិច្ចចែករំលែក
- ការផ្ដល់មូលនិធិជាក្រុម
- ប្រាក់ចំណូលសេវាកម្មផ្ទាល់ខ្លួន
- ចំណូលពីបរទេស និងការវិនិយោគក្រៅប្រទេស
- ការប្រាក់ពីគណនីធនាគារ
- ទ្រព្យសម្បត្តិជួលរបស់អ្នក។
- ភាគលាភទីផ្សារភាគហ៊ុន
- ប្រាក់ឧបត្ថម្ភរបស់រដ្ឋាភិបាល
- ប្រាក់ (ក្នុងករណីខ្លះទំនិញ ឬសេវាកម្មបានទទួលបានជំនួសឱ្យប្រាក់)
- ប្រាក់ចំណូលពីភាពជាដៃគូ មូលនិធិ និងអង្គភាព

DE-20789-4-ENG

## ព័ត៌មានបំពេញជាមុន និងសេចក្តីប្រកាសប្រាក់ចំណូល

វាកាន់តែងាយស្រួល ប្រសិនបើអ្នករង់ចាំសេចក្តីប្រកាសប្រាក់ចំណូលរបស់អ្នកមានសញ្ញាគូសថា 'ត្រៀមរួចសម្រាប់ការទូទាត់ពន្ធ(tax ready)' ហើយរង់ចាំឱ្យគេបំពេញព័ត៌មានរបស់អ្នកជាមុន មុនពេលអ្នកដាក់ពាក្យទូទាត់ពន្ធរបស់អ្នក។ អ្នកដែលមិនរង់ចាំឱ្យគេបំពេញព័តមានរបស់ពួកគេនឹងជួបការពន្យាពេលការទូទាត់ពន្ធរបស់ពួកគេជារឿយៗនៅក្នុងប្រព័ន្ធ ហើយអាចត្រូវការកែការទូទាត់ពន្ធរបស់ពួកគេ ពីព្រោះប្រាក់ចំណូលរបស់ពួកគេទាំងអស់មិនបានដាក់បញ្ចូលទេ។

ព័ត៌មានមួយចំនួនអាចចំណាយពេលយូរដើម្បីបំពេញជាមុនជាងព័ត៌មានផ្សេងទៀត។ សូមពិនិត្យមើលថាអ្វីដែលអ្នកត្រូវប្រកាសត្រូវបានដាក់បញ្ចូល និងត្រឹមត្រូវមុនពេលអ្នកដាក់ពាក្យ។

ប្រសិនបើអ្នកដាក់ពាក្យទូទាត់ពន្ធរបស់អ្នក នៅមុនពេលដែលព័ត៌មានរបស់អ្នកត្រូវបានបំពេញជាមុន អ្នកនឹងត្រូវមានកំណត់ត្រាដែលបញ្ជាក់ពីការទាមទារណាមួយសម្រាប់ពន្ធដែលដកហូតពីPAYGWTFN និងឥណទានប្រាក់ពន្ធដែលមិនត្រូវបានបំពេញជាមុននៅក្នុងការទូទាក់ពន្ធរបស់អ្នក។ អ្នកត្រូវប្រាកដថាចំនួនទឹកប្រាក់ទាំងនេះត្រូវបានដកដោយនិយោជក ឬភាគីទីបីរបស់អ្នក មុនពេលអ្នកដាក់ពាក្យ។

## ប្រាក់ឧត្តម្ភរបស់រដ្ឋាភិបាល

ប្រសិនបើអ្នកបានទទួលប្រាក់ឧត្តម្ភរបស់រដ្ឋាភិបាល (ឧ. ពីCentrelink) អ្នកប្រហែលជាត្រូវបញ្ចូលវាទៅក្នុងរបាយការណ៍ទូទាត់ពន្ធរបស់អ្នក។ សូមមើលព័ត៌មានខាងក្រោមដើម្បីដឹងថាអ្នកត្រូវធ្វើអ្វី។

### ប្រាក់ជំនួយសម្រាប់គ្រោះមហន្តរាយធម្មជាតិ

ប្រសិនបើអ្នកជួបប្រទះការលំបាកផ្នែកហិរញ្ញវត្ថុដោយសារគ្រោះមហន្តរាយធម្មជាតិ អ្នកប្រហែលជាបានទទួលប្រាក់ជំនួយសង្គ្រោះពី៖

- ទីភ្នាក់ងាររដ្ឋាភិបាលមូលដ្ឋាន រដ្ឋ ឬសហព័ន្ធ
- ក្រុមសប្បុរសធម៌ ឬសហគមន៍
- និយោជករបស់អ្នក។

### ប្រាក់ឧត្តម្ភសម្រាប់ការស្តារឡើងវិញពីគ្រោះមហន្តរាយរបស់រដ្ឋាភិបាលអូស្ត្រាលី

អ្នកប្រហែលជាបានទទួលប្រាក់ឧត្តម្ភសម្រាប់ការស្តារឡើងវិញពីគ្រោះមហន្តរាយរបស់រដ្ឋាភិបាលអូស្ត្រាលី (AGDRP)ឬប្រាក់ឧត្តម្ភសម្រាប់ការស្តារឡើងវិញពីគ្រោះមហន្តរាយសម្រាប់រយៈពេលខ្លី (DRA)ពីServices Australiaប្រសិនបើអ្នកបាត់បង់ប្រាក់ចំណូលដោយសារផលប៉ះពាល់ដោយផ្ទាល់នៃគ្រោះមហន្តរាយធម្មជាតិ។

ប្រាក់ឧបត្ថម្ភរបស់AGDRPគឺជាប្រាក់ចំណូលលើកលែងពន្ធ។ នេះមានន័យថាវាមិនជាប់ពន្ធទេ ហើយអ្នកមិនចាំបាច់បញ្ចូលវាទៅក្នុងរបាយការណ៍ទូទាត់ពន្ធរបស់អ្នកទេ។

ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើអ្នកបានពន្យាការខាតបង់ពីឆ្នាំប្រាក់ចំណូលមុន សម្រាប់ទូទាត់នៅឆ្នាំក្រោយ (ជាភាសាអង់គ្លេស)  អ្នកនឹងត្រូវកាត់បន្ថយចំនួននោះដោយប្រាក់ចំណូលលើកលែងពន្ធណាមួយ។

### ប្រាក់ឧត្តម្ភសម្រាប់ការស្តារឡើងវិញពីគ្រោះមហន្តរាយ

ប្រាក់ឧត្តម្ភសម្រាប់ការស្តារឡើងវិញពីគ្រោះមហន្តរាយ ជាទូទៅគឺជាប្រាក់ឧត្តម្ភជាប់ពន្ធ ដែលមានន័យថា អ្នកបង់ពន្ធលើចំនួនទឹកប្រាក់ដែលអ្នកបានទទួល ហើយអ្នកត្រូវបញ្ចូលវាដោយដៃនៅក្នុងរបាយការណ៍ទូទាត់ពន្ធរបស់អ្នក។

ទោះជាយ៉ាងណាក៏ដោយ រដ្ឋាភិបាលអាចធ្វើការលើកលែងប្រាក់ឧត្តម្ភសម្រាប់ការស្តារឡើងវិញពីគ្រោះមហន្តរាយជាក់លាក់ ឬប្រាក់ឧត្តម្ភមិនលើកលែងពន្ធដែលមិនអាចវាយតម្លៃបាន។

**ការប្រកាសបដិសេធទំនួលខុសត្រូវ៖** ព័ត៌មាននេះគឺជាសេចក្តីសង្ខេបទូទៅតែប៉ុណ្ណោះ ហើយមានបច្ចុប្បន្នភាពនៅថ្ងៃទី 26 ខែមីនា ឆ្នាំ 2024

អ្នកមានសេរីភាពក្នុងការថតចម្លង កែសម្រួល កែប្រែ បញ្ជូន និងចែកចាយឯកសារនេះតាមបំណងរបស់អ្នក (ប៉ុន្តែមិនមែនតាមរបៀបណាមួយដែលបង្ហាញថាATOឬCommonwealthគាំទ្រអ្នក ឬសេវាកម្ម ឬផលិតផលណាមួយរបស់អ្នក)។

ឧទាហរណ៍នៃប្រាក់ឧត្ថម្ភនេះគឺប្រាក់ឧត្ថម្ភជួយសង្គ្រោះពីគ្រោះមហន្តរាយភ្លើងឆេះព្រៃឆ្នាំ 2019-20 និងអត្ថប្រយោជន៍មិនមែនសាច់ប្រាក់នានា។

ប្រាក់ឧត្ថម្ភសម្រាប់ការស្តារឡើងវិញពីគ្រោះមហន្តរាយដែលបានបង់នឹង **មិន** បង្ហាញនៅលើរបាយការណ៍សង្ខេបនៃប្រាក់ចំណូលរបស់Centrelinkរបស់អ្នកទេ ហើយនឹង មិន ត្រូវបានបំពេញជាមុនទៅក្នុងរបាយការណ៍ទូទាត់ពន្ធរបស់អ្នកទេ។ អ្នកនឹងត្រូវពិនិត្យមើលចំនួនទឹកប្រាក់ដែលអ្នកបានទទួល៖

- នៅក្នុងផ្នែក**ប្រវត្តិការបង់ប្រាក់ឧត្ថម្ភ**នៃគណនីអនឡាញCentrelink របស់អ្នក។
- នៅក្នុងលិខិតCentrelinkដែលអ្នកបានទទួលតាមអនឡាញ ឬតាមប្រៃសណីយ៍
- ដោយទាក់ទងServices Australia

នៅពេលបំពេញរបាយការណ៍ទូទាត់ពន្ធរបស់អ្នក សូមបញ្ចូលប្រាក់ឧត្ថម្ភសម្រាប់ការស្តារឡើងវិញពីគ្រោះមហន្តរាយដែលអ្នកបានទទួលនៅផ្នែកណាមួយដូចខាងក្រោម៖

- **ប្រាក់ឧបត្ថម្ភ និងការបង់ប្រាក់របស់រដ្ឋាភិបាលអូស្ត្រាលី** ប្រសិនបើអ្នកដាក់ពាក្យតាមអនឡាញ ដោយប្រើmyTax
- **សំណួរទី 5 ប្រាក់ឧបត្ថម្ភ និងការបង់ប្រាក់របស់រដ្ឋាភិបាលអូស្ត្រាលី**ប្រសិនបើអ្នកដាក់ពាក្យតាមក្រដាស
- **សំណួរទី 5A ប្រាក់ឧបត្ថម្ភ និងការបង់ប្រាក់របស់រដ្ឋាភិបាលអូស្ត្រាលី** ប្រសិនបើអ្នកជាអ្នកជំនាញផ្នែកពន្ធដារដែលបានចុះឈ្មោះក្នុងបញ្ជី។

### ប្រាក់បន្ថែមលើប្រាក់ឧបត្ថម្ភសម្រាប់ការស្តារឡើងវិញពីគ្រោះមហន្តរាយ

ប្រាក់បន្ថែមលើប្រាក់ឧបត្ថម្ភសម្រាប់ការស្តារឡើងវិញពីគ្រោះមហន្តរាយ ប្រាក់ឧបត្ថម្ភការស្តារឡើងវិញនូវគ្រោះមហន្តរាយប្រទេសនូវែលសេឡង់និងប្រាក់បន្ថែមលើប្រាក់ឧបត្ថម្ភការស្តារឡើងវិញពីគ្រោះមហន្តរាយប្រទេសនូវែលសេឡង់ គឺជាប្រាក់ជាប់ពន្ធ ដែលមានន័យថាអ្នកបង់ពន្ធលើចំនួនទាំងនេះ ហើយអ្នកត្រូវបញ្ចូលវាទៅក្នុងរបាយការណ៍ទូទាត់ពន្ធរបស់អ្នកដោយដៃ។

ប្រាក់ឧត្ថម្ភទាំងនេះនឹង **មិន** បង្ហាញនៅលើរបាយការណ៍សង្ខេបនៃប្រាក់ចំណូលCentrelinkរបស់អ្នកទេ ហើយនឹង មិន ត្រូវបានបំពេញជាមុនទៅក្នុងរបាយការណ៍ទូទាត់ពន្ធរបស់អ្នកទេ។ អ្នកអាចពិនិត្យមើលចំនួនទឹកប្រាក់ដែលអ្នកបានទទួល៖

- នៅក្នុងផ្នែក**ប្រវត្តិការបង់ប្រាក់ឧត្ថម្ភ**នៃគណនីអនឡាញCentrelink របស់អ្នក។
- នៅក្នុងលិខិតCentrelinkដែលអ្នកបានទទួលតាមអនឡាញ ឬតាមប្រៃសណីយ៍
- ដោយទាក់ទងServices Australia

នៅពេលបំពេញរបាយការណ៍ទូទាត់ពន្ធរបស់អ្នក សូមបញ្ចូលប្រាក់ឧត្ថម្ភទាំងនេះនៅផ្នែកណាមួយដូចខាងក្រោម៖

- **ប្រាក់ឧបត្ថម្ភ និងការបង់ប្រាក់របស់រដ្ឋាភិបាលអូស្ត្រាលី** ប្រសិនបើអ្នកដាក់ពាក្យតាមអនឡាញ ដោយប្រើmyTax
- **សំណួរទី 24 ប្រាក់ចំណូលផ្សេងទៀត** ប្រសិនបើអ្នកដាក់ពាក្យតាមក្រដាស
- **សំណួរ 24V** ឬបន្ថែម**តារាងពេលនៃព័ត៌មានលំអិតអំពីប្រាក់ចំណូល** នៅផ្នែក**ចំនួនទឹកប្រាក់ដែលត្រូវបង់ពន្ធលើអត្ថប្រយោជន៍នានារបស់រដ្ឋាភិបាលអូស្ត្រាលី** (INCDTLS128)ជាមួយនឹងផ្នែក**ប្រភេទអត្ថប្រយោជន៍របស់រដ្ឋាភិបាលអូស្ត្រាលី** (INCDTLS126) ដែលបានកំណត់ថា**ពិសេស** ប្រសិនបើអ្នកជាអ្នកជំនួញផ្នែកពន្ធដារដែលបានចុះឈ្មោះក្នុងបញ្ជី។

## ប្រាក់ចំណាយដែលអាចកាត់កងចេញពីពន្ធដែលអ្នកអាចទាមទារបាន

អ្នកប្រហែលជាអាចទាមទារប្រាក់ចំណាយដែលអាចការកាត់កងពីពន្ធសម្រាប់ការចំណាយមួយចំនួនទាក់ទងនឹងការងាររបស់អ្នក។ ត្រូវប្រាកដថាអ្នកពិនិត្យមើលការចំណាយទាក់ទងនឹងការងាររបស់អ្នកទាំងអស់ ជាពិសេសប្រសិនបើការរៀបចំការងាររបស់អ្នកបានផ្លាស់ប្តូរ។

**ការប្រកាសបដិសេធទំនួលខុសត្រូវ៖** ព័ត៌មាននេះគឺជាសេចក្តីសង្ខេបទូទៅតែប៉ុណ្ណោះ ហើយមានបច្ចុប្បន្នភាពនៅថ្ងៃទី 26 ខែមីនា ឆ្នាំ 2024

អ្នកមានសេរីភាពក្នុងការថតចម្លង កែសម្រួល កែប្រែ បញ្ជូន និងចែកចាយឯកសារនេះតាមបំណងរបស់អ្នក (ប៉ុន្តែមិនមែនតាមរបៀបណាមួយដែលបង្ហាញថាATOឬCommonwealthគាំទ្រអ្នក ឬសេវាកម្ម ឬផលិតផលណាមួយរបស់អ្នក)។

កុំគ្រាន់តែបញ្ចូលចំនួនទឹកប្រាក់ដែលអ្នកបានទាមទារកាលពីឆ្នាំមុន។
ដើម្បីទាមទារប្រាក់ចំណាយដែលអាចការកាត់កងពីពន្ធ អ្នកត្រូវតែបានចំណាយប្រាក់
ហើយមិនត្រូវបានបង់សងវិញនូវការចំណាយនោះទេ។ វាត្រូវតែទាក់ទងដោយផ្ទាល់ទៅនឹងការរកប្រាក់ចំណូលរបស់អ្នក
ហើយអ្នកត្រូវតែមានកំណត់ត្រា ដូចជាបង្កាន់ដៃ ដើម្បីបញ្ជាក់វា។ របាយការណ៍ធនាគារ (តែមួយ)
ជាទូទៅមិនមានភស្តុតាងគ្រប់គ្រាន់ដើម្បីទាមទារប្រាក់ចំណាយដែលអាចកាត់កងពីពន្ធសម្រាប់ការចំណាយទាក់ទង
នឹងការងារនោះទេ។

## ប្រាក់ចំណាយដែលអាចកាត់កងពីពន្ធសម្រាប់ការធ្វើការងារពីផ្ទះ

មានវិធី 2
យ៉ាងដែលអ្នកអាចគណនាប្រាក់ចំណាយដែលអាចកាត់កងពីពន្ធ(ជាភាសាអង់គ្លេស)សម្រាប់ការធ្វើការងារពីផ្ទះ -
វិធីគណនាអត្រាថេរ(ជាភាសាអង់គ្លេស) ឬវិធីគណនាតម្លៃពិត (ជាភាសាអង់គ្លេស)។

វិធីគណនាអត្រាថេរអនុញ្ញាតឱ្យអ្នកទាមទារប្រាក់67សេនសម្រាប់រាល់ម៉ោងដែលអ្នកធ្វើការពីផ្ទះ
និងគ្របដណ្តប់លើការចំណាយសម្រាប់ដំណើរការបន្ថែមដូចខាងក្រោម៖

- ទិន្នន័យ និងអ៊ីនធឺណិត
- ការប្រើប្រាស់ទូរសព្ទចល័ត និងទូរសព្ទផ្ទះ
- អគ្គិសនី និងឧស្ម័ន
- សម្ភារៈការិយាល័យ
- គ្រឿងប្រើប្រាស់កុំព្យូទ័រ (ឧទាហរណ៍ទឹកថ្នាំម៉ាស៊ីនព្រីន)។

អ្នកមិនអាចទាមទាររបស់ទាំងនេះដោយឡែកពីគ្នាក្នុងរបាយការណ៍ទូទាត់ពន្ធរបស់អ្នកបានទេ។

ដើម្បីទាមទារប្រាក់ចំណាយដែលអាចកាត់កងពីពន្ធដោយប្រើវិធីគណនារអត្រាថេរ
អ្នកនឹងត្រូវមានកំណត់ត្រាដែលបង្ហាញពី៖

- ចំនួនម៉ោងសរុបដែលអ្នកធ្វើការពីផ្ទះនៅចន្លោះថ្ងៃទី 1 ខែកក្កដា ឆ្នាំ 2023 ដល់ថ្ងៃទី 30 ខែមិថុនា ឆ្នាំ 2024និង
- កំណត់ត្រាសម្រាប់ការចំណាយលើដំណើរការបន្ថែមនីមួយៗដែលគ្របដណ្តប់ដោយអត្រាក្នុងមួយម៉ោងដែលអ្នកបានកើតឡើង (ឧទាហរណ៍ វិក្កយបត្រទូរស័ព្ទ អគ្គិសនី ឬអ៊ីនធឺណិត)។

ដើម្បីប្រើវិធីគណនាតម្លៃពិត អ្នកនឹងត្រូវការកំណត់ត្រានៃម៉ោងដែលអ្នកធ្វើការនៅផ្ទះ
សម្រាប់ការចំណាយជាក់ស្តែងទាំងអស់ដែលអ្នកបង់
និងដែលបង្ហាញពីរបៀបដែលអ្នកគណនាផ្នែកដែលទាក់ទងនឹងការងារនៃការចំណាយទាំងនោះ។

## ការផ្លាស់ប្តូរអត្រាសេនក្នុងមួយគីឡូម៉ែត្រ

ប្រសិនបើអ្នកមានសិទ្ធិទាមទារប្រាក់ចំណាយដែលអាចកាត់កងពីពន្ធសម្រាប់ការចំណាយលើរថយន្តដែលទាក់ទងនឹង
ការងារ
អត្រាសេនក្នុងមួយគីឡូម៉ែត្រឥឡូវនេះបានកើនឡើងដល់85សេនក្នុងមួយគីឡូម៉ែត្រសម្រាប់ឆ្នាំប្រាក់ចំណូល2023-
24។ អ្នកអាចទាមទាររហូតដល់អតិបរមា 5.000 គីឡូម៉ែត្រទាក់ទងនឹងការងារក្នុងមួយឡានក្នុងមួយឆ្នាំ។

អត្រាសេនក្នុងមួយគីឡូម៉ែត្រគឺជាអត្រារួមបញ្ចូលទាំងអស់
ហើយគ្របដណ្តប់លើការចំណាយលើរថយន្តដែលប្រើប្រាស់សម្រាប់ការងាររបស់អ្នកទាំងអស់ រួមទាំងការចុះបញ្ជី
ការធានារ៉ាប់រង ការជួសជុល ការថែទាំ ប្រេងឥន្ធនៈ និងការធ្លាក់ចុះនៃតម្លៃ។ អ្នកមិនអាចទាមទារថ្លៃចំណាយទាំង
នេះដោយឡែកពីគ្នាក្នុងរបាយការណ៍ទូទាត់ពន្ធរបស់អ្នកបានទេ។
អ្នកនឹងត្រូវការកំណត់ត្រាដែលបង្ហាញថាអ្នកជាម្ចាស់ ឬជួលរថយន្ត
និងកំណត់ត្រាបង្ហាញពីរបៀបដែលអ្នកតាមដានគីឡូម៉ែត្រដែលទាក់ទងនឹងការងាររបស់អ្នកពេញមួយឆ្នាំ។

**ការប្រកាសបដិសេធទំនួលខុសត្រូវ៖** ព័ត៌មាននេះគឺជាសេចក្តីសង្ខេបទូទៅតែប៉ុណ្ណោះ ហើយមានបច្ចុប្បន្នភាពនៅថ្ងៃទី 26 ខែមីនា ឆ្នាំ 2024

អ្នកមានសេរីភាពក្នុងការថតចម្លង កែសម្រួល កែប្រែ បញ្ជូន និងចែកចាយឯកសារនេះតាមបំណងរបស់អ្នក
(ប៉ុន្តែមិនមែនតាមរបៀបណាមួយដែលបង្ហាញថាATOឬCommonwealthគាំទ្រអ្នក ឬសេវាកម្ម ឬផលិតផលណាមួយរបស់អ្នក)។

ព័ត៌មានបន្ថែម

សូមចូលទៅកាន់ato.gov.au/TaxTimeResources(ជាភាសាអង់គ្លេស)
សម្រាប់រកឯកសារស្តីពីពេលទូទាត់ពន្ធបន្ថែមជាភាសាផ្សេង។

## កម្មវិធីTax Help

ប្រសិនបើអ្នកត្រូវការជំនួយក្នុងការដាក់ពាក្យទូទាត់ពន្ធរបស់អ្នក ហើយអ្នកទទួលបានប្រាក់ចំណូលចំនួន 60.000ដុល្លារ ឬតិចជាងនេះក្នុងមួយឆ្នាំ អ្នកស្ម័គ្រចិត្តកម្មវិធីTax Help ដែលបានទទួលការបណ្តុះបណ្តាលត្រឹមត្រូវរបស់យើងអាចជួយអ្នកក្នុងការដាក់ពាក្យទូទាត់ពន្ធរបស់អ្នកដោយឥតគិតថ្លៃ។

សម្រាប់ព័ត៌មានបន្ថែមអំពីកម្មវិធី Tax Help សិទ្ធិទទួលបាន និងរបៀបកក់ការណាត់ជួប សូមចូលទៅកាន់ www.ato.gov.au/taxhelp (ជាភាសាអង់គ្លេស)។

ប្រសិនបើអ្នកមិនមានសិទ្ធិទទួលបានសេវាកម្មពីកម្មវិធី Tax Helpទេ អ្នកប្រហែលជាអាចប្រើកម្មវិធី National Tax Clinic ដែលជាគំនិតផ្តួចផ្តើមដែលទទួលមូលនិធិពីរដ្ឋាភិបាលដើម្បីជួយដល់អ្នកដែលប្រហែលជាមិនមានលទ្ធភាពទទួលបានដំបូន្មានប្រកបដោយវិជ្ជាជីវៈ និងតំណាងទាក់ទងជាមួយនឹងកិច្ចការពន្ធរបស់ពួកគេ។

សម្រាប់ព័ត៌មានបន្ថែមអំពី Tax Clinics សូមចូលទៅកាន់ ato.gov.au/taxclinic (ជាភាសាអង់គ្លេស)។

**ការប្រកាសបដិសេធទំនួលខុសត្រូវ៖** ព័ត៌មាននេះគឺជាសេចក្តីសង្ខេបទូទៅតែប៉ុណ្ណោះ ហើយមានបច្ចុប្បន្នភាពនៅថ្ងៃទី 26 ខែមីនា ឆ្នាំ 2024

អ្នកមានសេរីភាពក្នុងការថតចម្លង កែសម្រួល កែប្រែ បញ្ជូន និងចែកចាយឯកសារនេះតាមបំណងរបស់អ្នក
(ប៉ុន្តែមិនមែនតាមរបៀបណាមួយដែលបង្ហាញថាATOឬCommonwealthគាំទ្រអ្នក ឬសេវាកម្ម ឬផលិតផលណាមួយរបស់អ្នក)។